# វិធីសាស្ត្រសម្រេចចិត្ត សម្រាប់ការពិនិត្យតាមដានរោគសញ្ញានិងការប៉ះពាល់នឹងមេរោគ នៅមណ្ឌលថែទាំនិងអប់រំកុមារតូច គ្រឹះស្ថានអប់រំ និងសាលារៀន TK-12

*នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles*
*បានធ្វើបច្ចុប្បន្នកម្ម៖ 9/20/2021*

# វិធីសាស្ត្រសម្រេចចិត្តសម្រាប់*កុមារ*ដែលមានរោគសញ្ញា

# វិធីសាស្ត្រសម្រេចចិត្តសម្រាប់កុមារដែលមានរោគសញ្ញាមុនចូល[1]ទៅក្នុងស្ថាប័នអប់រំ ដោយមិនគិតពីស្ថានភាពចាក់ថ្នាំបង្ការ

[1]ប្រសិនបើកុមារមិនស្រួលខ្លួននៅឯទីតាំងនោះ សូមដាក់កុមារឱ្យនៅដាច់ដោយឡែក (ឆ្ងាយពីអ្នកអ្នកមើលថែ យកល្អដាក់កុមារទីធ្លាខាងក្រៅ) ហើយអនុវត្តតាមវិធីសាស្ត្រសម្រេចចិត្តដូចដែលបានពិពណ៌នាខាងក្រោម។

ការពិនិត្យកំណត់កុមារដែលមានរោគសញ្ញា 1 ឬច្រើនជាងនេះដែលទំនងជាស្របទៅនឹងរោគសញ្ញានៃ<u>ជំងឺ COVID-19</u>។[1] →

កុមារត្រូវបញ្ជូនទៅផ្ទះវិញ។ ឪពុកម្តាយ/អាណាព្យាបាលត្រូវបានណែនាំឱ្យពិគ្រោះជាមួយអ្នកផ្តល់សេវាវេជ្ជសាស្ត្រសម្រាប់ការវាយតម្លៃបន្ថែមទៀត និងអាចមានការធ្វើតេស្តរកជំងឺ COVID-19។

- អ្នកផ្តល់សេវាវេជ្ជសាស្ត្របញ្ជាក់ថាកុមារមិនមានរោគសញ្ញាដែលទំនងជាដូចទៅនឹងរោគសញ្ញានៃជំងឺ COVID-19។ → កុមារត្រូវនៅផ្ទះដោយអនុវត្តតាមសេចក្តីណែនាំរបស់អ្នកផ្តល់សេវាវិជ្ជសាស្ត្រ។
- មិនបានពិគ្រោះជំងឺជាមួយអ្នកផ្តល់សេវាវេជ្ជសាស្ត្រ ឬអ្នកផ្តល់សេវាវេជ្ជសាស្ត្របញ្ជាក់ថា កុមារមានរោគសញ្ញាស្របទៅនឹងជំងឺ COVID-19។
  - កុមារបានធ្វើតេស្តរកមេរោគ:
    - កុមារទទួលលទ្ធផល **អវិជ្ជមាន** ពីការធ្វើតេស្តម៉ូលេគុល (molecular test) រកមេរោគ COVID-19 → កុមារត្រូវនៅផ្ទះរហូតដល់លែងមានគ្រុនក្តៅ ដោយមិនថ្នាំបញ្ចុះកម្តៅរយៈពេល 24 ម៉ោង និងរោគសញ្ញាកាន់តែធូរស្បើយឡើង។
    - កុមារទទួលលទ្ធផល **វិជ្ជមាន** ពីការធ្វើតេស្តត្រួតពិនិត្យជំងឺ COVID-19 → កុមារត្រូវអនុវត្តតាម<u>សេចក្តីណែនាំការដាក់ឱ្យនៅដាច់ដោយឡែកនៅផ្ទះ</u>។
  - កុមារមិនបានធ្វើតេស្តរកមេរោគ → កុមារត្រូវអនុវត្តតាម<u>សេចក្តីណែនាំការដាក់ឱ្យនៅដាច់ដោយឡែកនៅផ្ទះ</u>។

ការពិនិត្យកំណត់អត្តសញ្ញាណកុមារដែលមិនបានចាក់ថ្នាំបង្ការដែលមានរោគសញ្ញា<u>មិន</u>ស្របទៅនឹងជំងឺ COVID-19។ →

ស្ថាប័នសម្រេចចិត្តក្នុងការកំណត់ថា តើកុមារគួរតែត្រូវបានលើកលែងតាមគោលការណ៍គ្រប់គ្រងជំងឺឬទេ។ ប្រសិនបើរោគសញ្ញារបស់កុមារធ្វើឱ្យមានការលំបាកក្នុងការអនុវត្តតាមពិធីការសុវត្ថិភាពសម្រាប់ COVID-19 នៅក្នុងទីតាំងនោះ កុមារគួរតែត្រូវបញ្ជូនទៅផ្ទះវិញ។

[1]រោគសញ្ញានានាដែលទំនងជាស្របទៅនឹងការឆ្លងជំងឺ COVID-19 ចំពោះកុមាររួមមាន៖ គ្រុនក្តៅលើសឬស្មើ (≥) 100.4°F ក្អកកើតឡើងថ្មី (ខុសគ្នាពីធម្មតាឬទូទៅ) រាគរូស ឬក្អួតចង្អោរ។ ប្រសិនបើរោគសញ្ញារបស់កុមារមិនទំនងជាស្របទៅនឹងជំងឺ COVID-19 ទេ ប៉ុន្តែនៅតែមានការព្រួយបារម្ភនោះ ត្រូវបានណែនាំឱ្យទទួលការវាយតម្លៃរបស់កុមារពីអ្នកផ្តល់សេវាវេជ្ជសាស្ត្រ។

# វិធីសាស្ត្រសម្រេចចិត្តសម្រាប់បុគ្គលដែលមិនបានចាក់ថ្នាំបង្ការ ហើយបានប៉ះពាល់ឬមានទំនាក់ទំនងជាមួយកុមារ[1] ដែលអាចមានឆ្លងមេរោគ នៅក្នុងស្ថាប័នអប់រំ

[1]**កុមារដែលអាចមានឆ្លងមេរោគ**គឺជាកុមារដែលមានរោគសញ្ញាលើសពីឬស្មើ (≥) 1 ដែលទំនងជាស្របទៅនឹងជំងឺ COVID-19។ **បុគ្គលដែលមានទំនាក់ទំនង**ជិតស្និទ្ធ**ជាមួយកុមារដែលអាចមានឆ្លងមេរោគ**គឺជាមនុស្សដែលស្ថិតនៅក្នុងបរិវេណ 6 ហ្វិតក្នុងពេលលើសពីឬស្មើ (≥) 15 នាទីក្នុងអំឡុងពេល 24 ម៉ោងជាមួយកុមារដែលអាចឆ្លងមេរោគ ឬប៉ះពាល់ដោយផ្ទាល់នឹងវត្ថុរាវ/សារធាតុបញ្ចេញពីរាងកាយផ្សេងៗ ពីកុមារដែលមានឆ្លងមេរោគនេះ។

បុគ្គលដែលមិនបានចាក់ថ្នាំបង្ការ ហើយបានប៉ះពាល់ឬមានទំនាក់ទំនងជាមួយកុមារដែលអាចមានឆ្លងមេរោគត្រូវបានជូនដំណឹងថាពួកគេអាចមានការប៉ះពាល់នឹងមេរោគ។

មនុស្សដែលមិនបានចាក់ថ្នាំបង្ការ ហើយបានប៉ះពាល់ឬមានទំនាក់ទំនងនឹងមេរោគអាចបន្តឋិតនៅក្នុងទីតាំងនោះបានខណៈពេលដែលកំពុងរង់ចាំ**ការបញ្ជាក់ពីការប៉ះពាល់នឹងមេរោគនោះ។**[2]

→ ស្ថាប័នបញ្ជាក់ថាបុគ្គលដែលមិនបានចាក់ថ្នាំបង្ការនោះបានប៉ះពាល់ទៅនឹងជំងឺ COVID-19។

→ បុគ្គលដែលបានប៉ះពាល់ឬមានទំនាក់ទំនង ត្រូវបានណែនាំឱ្យធ្វើចត្តាឡីស័កនិងធ្វើតេស្តរកមេរោគ

- បុគ្គលដែលបានប៉ះពាល់ឬមានទំនាក់ទំនងទទួលលទ្ធផល**វិជ្ជមាន**ពីការធ្វើតេស្តត្រួតពិនិត្យជំងឺ COVID-19 → បុគ្គលដែលបានប៉ះពាល់ឬមានទំនាក់ទំនងគឺចាត់ទុកជាករណីមួយឥឡូវ ហើយគួរតែអនុវត្តតាមសេចក្តីណែនាំនៃការដាក់ឱ្យនៅដាច់ដោយឡែកនៅផ្ទះ។
- បុគ្គលដែលបានប៉ះពាល់ ឬមានទំនាក់ទំនងមិនធ្វើតេស្តរកមេរោគ ឬទទួលលទ្ធផល**អវិជ្ជមាន**ពីការធ្វើតេស្តត្រួតពិនិត្យជំងឺ COVID-19 → បុគ្គលដែលបានប៉ះពាល់ឬមានទំនាក់ទំនងតាមអនុវត្តតាមសេចក្តីណែនាំនៃការធ្វើចត្តាឡីស័កនៅផ្ទះ។

→ ស្ថាប័នបញ្ជាក់ថា បុគ្គលដែលមិនបានចាក់ថ្នាំបង្ការមិនបានប៉ះពាល់មេរោគ ឬក៏គ្មានការផ្តល់ការបញ្ជាក់ពីការប៉ះពាល់នឹងមេរោគ។ **មិនតម្រូវឱ្យធ្វើសកម្មភាពអ្វីទេ។**

[2]**ការប៉ះពាល់មេរោគត្រូវបានបញ្ជាក់**សម្រាប់បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយកុមារដែលអាចមានឆ្លងមេរោគ ប្រសិនបើទីតាំងនោះទទួលបានដំណឹងថាកុមារដែលអាចមានឆ្លងមេរោគនោះ ទទួលលទ្ធផលវិជ្ជមានពីការធ្វើតេស្តត្រួតពិនិត្យជំងឺ COVID-19 ឬក៏ទទួលការធ្វើរោគវិនិច្ឆ័យជំងឺ COVID-19 ពីអ្នកផ្តល់សេវាវេជ្ជសាស្ត្រ។

# វិធីសាស្ត្រសម្រេចចិត្តសម្រាប់បុគ្គលដែលបានចាក់ថ្នាំបង្ការពេញលេញ ហើយបានប៉ះពាល់ឬមានទំនាក់ទំនងជាមួយកុមារ[1]ដែលអាចជាឆ្លងមេរោគ នៅក្នុងស្ថាប័នអប់រំ

[1]**កុមារដែលអាចមានឆ្លងមេរោគ**គឺជាកុមារដែលមានរោគសញ្ញាលើសពីឬស្មើ (≥) 1 ដែលទំនងជាស្របទៅនឹងជំងឺ COVID-19។ **បុគ្គលដែលមានទំនាក់ទំនង**ជិតស្និទ្ធ**ជាមួយកុមារដែលអាចមានឆ្លងមេរោគ**គឺជាមនុស្សដែលស្ថិតនៅក្នុងបរិវេណ 6 ហ្វីតក្នុងពេលលើសពីឬស្មើ (≥) 15 នាទីក្នុងអំឡុងពេល 24 ម៉ោងជាមួយកុមារដែលអាចឆ្លងមេរោគ ឬប៉ះពាល់ដោយផ្ទាល់នឹងវត្ថុរាវ/សារធាតុបញ្ចេញពីរាងកាយផ្សេងៗ ពីកុមារដែលមានឆ្លងមេរោគនេះ។

បុគ្គលដែលបានចាក់ថ្នាំបង្ការ ហើយបានប៉ះពាល់ឬមានទំនាក់ទំនងជាមួយកុមារដែលអាចមានឆ្លងមេរោគត្រូវបានជូនដំណឹងថាពួកគេអាចមានការប៉ះពាល់នឹងមេរោគ។

បុគ្គលដែលបានចាក់ថ្នាំបង្ការ ហើយបានប៉ះពាល់ឬមានទំនាក់ទំនងអាចបន្តឋិតនៅទីតាំងនោះបាន ខណៈពេលដែលកំពុងរង់ចាំ**ការបញ្ជាក់ពីការប៉ះពាល់នឹងមេរោគនោះ។**[2]

→ ស្ថាប័នបញ្ជាក់ថាបុគ្គលដែលបានចាក់ថ្នាំបង្ការនោះបានប៉ះពាល់ទៅនឹងជំងឺ COVID-19។

ណែនាំឱ្យធ្វើតេស្តរកមេរោគ នៅពេលដែលមានការចម្លងក្នុងសហគមន៍ខ្ពស់

- បុគ្គលដែលបានប៉ះពាល់ឬមានទំនាក់ទំនង ទទួលលទ្ធផល **វិជ្ជមាន**ពីការធ្វើតេស្តត្រួតពិនិត្យជំងឺ COVID-19 → បុគ្គលដែលបានប៉ះពាល់ឬមានទំនាក់ទំនងគឺចាត់ទុកជាករណីមួយឥឡូវ ហើយគួរតែអនុវត្តតាមសេចក្តីណែនាំនៃការដាក់ឱ្យនៅដាច់ដោយឡែកនៅផ្ទះ។
- បុគ្គលដែលបានប៉ះពាល់ឬមានទំនាក់ទំនង មិនធ្វើតេស្តរកមេរោគ ឬទទួលលទ្ធផល **អវិជ្ជមាន**ពីការធ្វើតេស្តត្រួតពិនិត្យជំងឺ COVID-19 → បុគ្គលដែលបានប៉ះពាល់ឬមានទំនាក់ទំនង មិនចាំបាច់ធ្វើចត្តាឡីស័កទេ។

→ ស្ថាប័នបញ្ជាក់ថាបុគ្គលដែលបានចាក់ថ្នាំបង្ការមិនប៉ះពាល់មេរោគ ឬក៏គ្មានការបញ្ជាក់ពីការប៉ះពាល់នឹងមេរោគ។ **មិនតម្រូវឱ្យធ្វើសកម្មភាពអ្វីទេ។**

[2]**ការប៉ះពាល់មេរោគត្រូវបានបញ្ជាក់**សម្រាប់បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយកុមារដែលអាចមានឆ្លងមេរោគ ប្រសិនបើទីតាំងនោះទទួលបានដំណឹងថាកុមារដែលអាចមានឆ្លងមេរោគនោះ ទទួលលទ្ធផលវិជ្ជមានពីការធ្វើតេស្តត្រួតពិនិត្យជំងឺ COVID-19 ឬក៏ទទួលការធ្វើរោគវិនិច្ឆ័យជំងឺ COVID-19 ពីអ្នកផ្តល់សេវាវេជ្ជសាស្ត្រ។

# វិធីសាស្ត្រសម្រេចចិត្តសម្រាប់*បុគ្គលិក*ដែលមានរោគសញ្ញា

# វិធីសាស្ត្រសម្រេចចិត្ត សម្រាប់បុគ្គលិកដែលមិនបានចាក់ថ្នាំបង្ការ ហើយមានរោគសញ្ញាមុនពេលចូល[1] ទៅក្នុងស្ថាប័នអប់រំ ដោយមិនគិតពីស្ថានភាពចាក់ថ្នាំបង្ការ

[1]ប្រសិនបើបុគ្គលិកមិនស្រួលខ្លួននៅកន្លែងការងារ សូមដាក់បុគ្គលិកឱ្យនៅទីតាំងដាច់ដោយឡែក (យកល្អដាក់បុគ្គលិកនៅទីធ្លាខាងក្រៅ រកគម្លាតរាងកាយពីអ្នកមើលថែផ្សេងទៀត) ហើយអនុវត្តតាមវិធីសាស្ត្រសម្រេចចិត្តដូចខាងក្រោម។

ការពិនិត្យកំណត់អត្តសញ្ញាណបុគ្គលិកដែលមានរោគសញ្ញា 1 ឬច្រើនជាងនេះ ដែលទំនងជាស្របទៅនឹងរោគសញ្ញានៃជំងឺ COVID-19។[1]

→ បុគ្គលិកត្រូវបញ្ជូនឱ្យត្រឡប់ទៅផ្ទះវិញ ហើយត្រូវបានណែនាំឱ្យពិគ្រោះជាមួយអ្នកផ្តល់សេវាវេជ្ជសាស្ត្រ សម្រាប់ការវាយតម្លៃបន្ថែមទៀត និងការធ្វើតេស្តរកជំងឺ COVID-19 ដែលអាចកើតមាន។

- អ្នកផ្តល់សេវាវេជ្ជសាស្ត្របញ្ជាក់ថាបុគ្គលិកមិនមានរោគសញ្ញាស្របទៅនឹងជំងឺ COVID-19 ទេ។
  → បុគ្គលិកត្រូវនៅផ្ទះដោយអនុវត្តតាមសេចក្តីណែនាំរបស់អ្នកផ្តល់សេវាវិជ្ជសាស្ត្រ។
- មិនបានពិគ្រោះយោបល់ជាមួយអ្នកផ្តល់សេវាវេជ្ជសាស្ត្រទេ ឬ អ្នកផ្តល់សេវាវេជ្ជសាស្ត្របញ្ជាក់ថាបុគ្គលិកមានរោគសញ្ញាស្របទៅនឹងជំងឺ COVID-19។
  - បុគ្គលិកបានធ្វើតេស្តរកមេរោគ
    - បុគ្គលិកទទួលលទ្ធផល **អវិជ្ជមាន**ពីការធ្វើតេស្តម៉ូលេគុល (molecular test) រកមេរោគ COVID-19
      → បុគ្គលិកត្រូវនៅផ្ទះរហូតដល់លែងមានគ្រុនក្តៅ ដោយមិនប្រើថ្នាំបញ្ចុះកម្តៅរយៈពេល 24 ម៉ោង និងរោគសញ្ញាកាន់តែធូរស្បើយឡើង។
    - បុគ្គលិកទទួលលទ្ធផល **វិជ្ជមាន**ពីការធ្វើតេស្តត្រួតពិនិត្យជំងឺ COVID-19
      → បុគ្គលិកត្រូវអនុវត្តតាម សេចក្តីណែនាំការដាក់ឱ្យនៅដាច់ដោយឡែកនៅផ្ទះ។
  - បុគ្គលិកមិនបានធ្វើតេស្តរកមេរោគ
    → បុគ្គលិកត្រូវអនុវត្តតាម សេចក្តីណែនាំការដាក់ឱ្យនៅដាច់ដោយឡែកនៅផ្ទះ។

ការពិនិត្យកំណត់អត្តសញ្ញាណបុគ្គលិកដែលមិនបានចាក់ថ្នាំបង្ការដែលមានរោគសញ្ញាមិនស្របទៅនឹងជំងឺ COVID-19។

→ ស្ថាប័នសម្រេចចិត្តក្នុងការកំណត់ថា តើបុគ្គលិកគួរតែត្រូវបានលើកលែងតាមគោលការណ៍គ្រប់គ្រងជំងឺឬទេ។ ប្រសិនបើរោគសញ្ញារបស់បុគ្គលិកធ្វើឱ្យមានការលំបាកក្នុងការអនុវត្តតាមពិធីការសុវត្ថិភាពសម្រាប់ COVID-19 នៅក្នុងទីតាំងនោះ បុគ្គលិកគួរតែត្រូវបញ្ជូនឱ្យត្រឡប់ទៅផ្ទះវិញ។

[1]រោគសញ្ញានានាដែលពាក់ព័ន្ធនឹងជំងឺ COVID-19 ចំពោះមនុស្សពេញវ័យមានដូចជាៈ គ្រុនក្តៅលើសពីឬស្មើ (≥) 100.4° ឬមានអារម្មណ៍ដូចគ្រុនក្តៅ (គ្រុនរងារ បែកញើស) ក្អក ដកដង្ហើមខ្លីៗ លែងដឹងរសជាតិឬក្លិនថ្មីៗ អស់កម្លាំង ហៀរសំបោរឬតឹងច្រមុះ ឈឺសាច់ដុំឬឈឺរាងកាយ ឈឺក្បាល ឈឺបំពង់ក ចង្អោរចង់ក្អួតឬក្អួត ឬរាគរូស។ ប្រសិនបើមានរោគសញ្ញាដែលមិនមាននៅក្នុងតារាងនេះទេ ប៉ុន្តែនៅតែមានការព្រួយបារម្ភ បានណែនាំឱ្យទទួលការវាយតម្លៃបន្ថែមដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្រ។

# វិធីសាស្ត្រសម្រេចចិត្តសម្រាប់បុគ្គលដែលមិនបានចាក់ថ្នាំបង្ការ ហើយបានប៉ះពាល់ឬមានទំនាក់ទំនងនឹងមេរោគពីបុគ្គលិក[1]ដែលអាចមានឆ្លងមេរោគនៅក្នុងស្ថាប័នអប់រំ

[1]**បុគ្គលិកដែលអាចមានឆ្លងមេរោគ**គឺជាបុគ្គលិកដែលមានរោគសញ្ញាលើសពីឬស្មើ (≥) 1 ដែលទំនងជាស្របទៅនឹងជំងឺ COVID-19។ **បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធិជាមួយបុគ្គលិកដែលអាចមានឆ្លងមេរោគ**គឺជាមនុស្សនៅទីតាំងនោះដែលស្ថិតនៅក្នុងបរិវេណ 6 ហ្វីតក្នុងពេលលើសពី 15 នាទីក្នុងអំឡុងពេល 24 ម៉ោងជាមួយបុគ្គលិកដែលអាចឆ្លងមេរោគ ឬប៉ះពាល់ដោយផ្ទាល់នឹងវត្ថុរាវ/សារធាតុបញ្ចេញពីរាងកាយផ្សេងៗ ពីបុគ្គលិកដែលមានមេរោគនេះ។

បុគ្គលដែលបានប៉ះពាល់ឬមានទំនាក់ទំនងនឹងបុគ្គលិកដែលអាចមានឆ្លងមេរោគត្រូវបានជូនដំណឹងថាពួកគេអាចមានការប៉ះពាល់នឹងមេរោគនៅទីតាំងនោះ។

បុគ្គលដែលមានការប៉ះពាល់ឬមានទំនាក់ទំនងនឹងមេរោគអាចបន្តឋិតនៅទីតាំងនោះខណៈពេលដែលកំពុងរង់ចាំ**ការបញ្ជាក់ពីការប៉ះពាល់នឹងមេរោគនោះ។**[2]

→ ស្ថាប័នបញ្ជាក់ថាបុគ្គលនោះបានប៉ះពាល់ទៅនឹងជំងឺ COVID-19។

→ ស្ថាប័នបញ្ជាក់ថាបុគ្គលនោះមិនបានប៉ះពាល់ទៅនឹងមេរោគ ឬក៏គ្មានការផ្តល់ការបញ្ជាក់ពីការប៉ះពាល់នឹងមេរោគ។ **មិនតម្រូវឱ្យធ្វើសកម្មភាពអ្វីទេ។**

បុគ្គលដែលបានប៉ះពាល់ឬមានទំនាក់ទំនងទៅនឹងមេរោគត្រូវបានណែនាំឱ្យធ្វើចត្តាឡីស័កនិងធ្វើតេស្តរកមេរោគ

- បុគ្គលដែលបានប៉ះពាល់ឬមានទំនាក់ទំនងទៅនឹងមេរោគគឺទទួលលទ្ធផល**វិជ្ជមាន**ពីការធ្វើតេស្តត្រួតពិនិត្យជំងឺ COVID-19 → បុគ្គលដែលបានប៉ះពាល់ឬមានទំនាក់ទំនងគឺចាត់ទុកជាករណីមួយតឡូវ ហើយគួរតែអនុវត្តតាមសេចក្តីណែនាំនៃការដាក់ឱ្យនៅដាច់ដោយឡែកនៅផ្ទះ។
- បុគ្គលដែលបានប៉ះពាល់ឬមានទំនាក់ទំនងមិនបានធ្វើតេស្តរកមេរោគ ឬទទួលលទ្ធផល**អវិជ្ជមាន**ពីការធ្វើតេស្តត្រួតពិនិត្យជំងឺ COVID-19 → បុគ្គលដែលបានប៉ះពាល់ឬមានទំនាក់ទំនងទៅនឹងមេរោគបន្តអនុវត្តតាមសេចក្តីណែនាំនៃការធ្វើចត្តាឡីស័កនៅផ្ទះ។

[2]**ការប៉ះពាល់មេរោគត្រូវបានបញ្ជាក់**សម្រាប់បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយបុគ្គលិកដែលអាចមានឆ្លងមេរោគ ប្រសិនបើទីតាំងនោះទទួលបានដំណឹងថាបុគ្គលិកដែលអាចមានឆ្លងមេរោគនោះ ទទួលលទ្ធផលវិជ្ជមានពីការធ្វើតេស្តត្រួតពិនិត្យជំងឺ COVID-19 ឬក៏ទទួលការធ្វើរោគវិនិច្ឆ័យជំងឺ COVID-19 ពីអ្នកផ្តល់សេវាវេជ្ជសាស្ត្រ។

# វិធីសាស្ត្រសម្រេចចិត្តសម្រាប់បុគ្គលដែលបានចាក់ថ្នាំបង្ការពេលពេញ ហើយបានប៉ះពាល់នឹងមេរោគពីបុគ្គលិក[1]ដែលទំនងមានឆ្លងមេរោគ នៅក្នុងស្ថាប័នអប់រំ

[1]**បុគ្គលិកដែលអាចមានឆ្លងមេរោគ**គឺជាបុគ្គលិកដែលមានរោគសញ្ញាលើសពី (≥) 1 ដែលទំនងជាស្របទៅនឹងជំងឺ COVID-19។ **បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយបុគ្គលិកដែលអាចមានឆ្លងមេរោគ**គឺជាមនុស្សនៅទីតាំងនោះដែលស្ថិតនៅក្នុងបរិវេណ 6 ហ្វីតក្នុងពេលលើសពី 15 នាទីក្នុងអំឡុងពេល 24 ម៉ោងជាមួយបុគ្គលិកដែលអាចឆ្លងមេរោគ ឬប៉ះពាល់ដោយផ្ទាល់នឹងវត្ថុរាវ/សារធាតុបញ្ចេញពីរាងកាយផ្សេងៗ ពីបុគ្គលិកដែលមានមេរោគនេះ។

បុគ្គលដែលបានប៉ះពាល់ឬមានទំនាក់ទំនងនឹងបុគ្គលិកដែលអាចមានឆ្លងមេរោគត្រូវបានជូនដំណឹងថាពួកគេអាចមានការប៉ះពាល់នឹងមេរោគនៅទីតាំងនោះ។

បុគ្គលដែលមានការប៉ះពាល់ឬមានទំនាក់ទំនងនឹងមេរោគអាចបន្តឋិតនៅទីតាំងនោះខណៈពេលដែលកំពុងរង់ចាំ**ការបញ្ជាក់ពីការប៉ះពាល់នឹងមេរោគនោះ។**[2]

→ ស្ថាប័នបញ្ជាក់ថាបុគ្គលនោះបានប៉ះពាល់ទៅនឹងជំងឺ COVID-19។

ការធ្វើតេស្តត្រូវបានណែនាំក្នុងអំឡុងដែលមានការឆ្លងក្នុងសហគមន៍ខ្ពស់

- បុគ្គលដែលមិនបានប៉ះពាល់ឬមានទំនាក់ទំនងទៅនឹងមេរោគគឺទទួលលទ្ធផល**វិជ្ជមាន**ពីការធ្វើតេស្តត្រួតពិនិត្យជំងឺ COVID-19 → បុគ្គលដែលបានប៉ះពាល់ឬមានទំនាក់ទំនងទៅនឹងមេរោគគឺចាត់ទុកជាករណីមួយគឡូរហើយគួរតែអនុវត្តតាមសេចក្តីណែនាំនៃការដាក់ឱ្យនៅដាច់ដោយឡែកនៅផ្ទះ។
- បុគ្គលដែលបានប៉ះពាល់ឬមានទំនាក់ទំនងទៅនឹងមេរោគ មិនបានធ្វើតេស្តរកមេរោគ ឬទទួលលទ្ធផល**អវិជ្ជមាន**ពីការធ្វើតេស្តត្រួតពិនិត្យជំងឺ COVID-19 → បុគ្គលដែលបានប៉ះពាល់ឬមានទំនាក់ទំនងមិនចាំបាច់ធ្វើចត្តាឡីស័កទេ។

→ ស្ថាប័នបញ្ជាក់ថាបុគ្គលនោះមិនបានប៉ះពាល់ទៅនឹងមេរោគ ឬក៏គ្មានការផ្តល់ការបញ្ជាក់ពីការប៉ះពាល់នឹងមេរោគ។ **មិនតម្រូវឱ្យធ្វើសកម្មភាពអ្វីទេ។**

[2] **ការប៉ះពាល់មេរោគត្រូវបានបញ្ជាក់**សម្រាប់បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយបុគ្គលិកដែលអាចមានឆ្លងមេរោគ ប្រសិនបើទីតាំងនោះទទួលបានដំណឹងថាបុគ្គលិកដែលអាចមានឆ្លងមេរោគនោះ ទទួលលទ្ធផលវិជ្ជមានពីការធ្វើតេស្តត្រួតពិនិត្យជំងឺ COVID-19 ឬក៏ទទួលការធ្វើរោគវិនិច្ឆ័យជំងឺ COVID-19 ពីអ្នកផ្តល់សេវាវេជ្ជសាស្ត្រ។

# វិធីសាស្ត្រធ្វើចត្តាឡីស័កសម្រាប់កុមារនិងបុគ្គលិកដែល *មានការប៉ះពាល់នឹងមេរោគ* នៅមណ្ឌលថែទាំនិងអប់រំកុមារតូច គ្រឹះស្ថានអប់រំ និងសាលារៀន TK-12

## កំណត់អត្តសញ្ញាណនៃការប៉ះពាល់នឹងមេរោគនៅក្នុងបរិវេណទីតាំង-បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធទៅនឹងករណីច្បាស់លាស់មួយ

**បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធ**គឺជាមនុស្សម្នាក់ដែលបានប៉ះពាល់ទៅនឹងអ្នកដែលត្រូវបានពិនិត្យឃើញថាមានជំងឺ COVID-19 ក្នុងអំឡុងពេលដែលអាចចម្លងបាន* ប្រសិនបើ**យ៉ាងហោចណាស់ចំណុចមួយ**ក្នុងចំណោមចំណុចខាងក្រោមបានកើតឡើង៖

- បុគ្គលម្នាក់នោះស្ថិតនៅក្នុងបរិវេណ 6 ហ្វីតពីមនុស្សដែលមានជំងឺ COVID-19 រយៈពេលសរុប 15 នាទី ឬយូរជាងនេះក្នុងអំឡុងពេល 24 ម៉ោង

ឬ

- បុគ្គលម្នាក់នោះបានប៉ះពាល់ទៅនឹងសារធាតុរាវនៃរាងកាយ និងឬសារធាតុបញ្ចេញផ្សេងៗ ពីបុគ្គលដែលមានជំងឺ COVID-19 ដោយមិនមានការការពារ។ ឧទាហរណ៍ ពួកគេត្រូវបានគេក្អកឬកណ្ដាស់ដាក់ ពួកគេបានប្រើពែងឬប្រដាប់ប្រដាបរិភោគរួមគ្នា ពួកគេបានថើបគ្នា ឬពួកគេបានផ្ដល់ការថែទាំដល់អ្នកដែលផ្ទុកមេរោគដោយមិនបានពាក់ឧបករណ៍ការពារត្រឹមត្រូវ។

- បុគ្គលដែលត្រូវបានគេចាត់ទុកថា **អាចចម្លងមេរោគបាន** ហើយអាចរាលដាលមេរោគទៅអ្នកដទៃបាន ចាប់ពី 2 ថ្ងៃ មុនពេលមានចាប់ផ្ដើមចេញរោគសញ្ញាដំបូង រហូតដល់ពេលបញ្ចប់នៃការដាក់ឱ្យនៅដាច់ដោយឡែក (ពោលគឺ 10 ថ្ងៃបានកន្លងផុតទៅចាប់តាំងពីពេលរោគសញ្ញាបានចាប់ផ្ដើម ហើយមិនមានគ្រុនក្ដៅយ៉ាងហោចណាស់ 24 ម៉ោង និងរោគសញ្ញាកាន់តែធូរស្បើយឡើង) ឬចាប់ពី 2 ថ្ងៃមុនពេលការធ្វើតេស្តទទួលលទ្ធផលថាវិជ្ជមានរបស់ពួកគេ រហូតដល់ 10 ថ្ងៃបន្ទាប់ពីការធ្វើតេស្តនោះ ប្រសិនបើរោគសញ្ញាមិនដែលកើតឡើង។

កំណត់សម្គាល់៖ បុគ្គលម្នាក់មិនគួរត្រូវបានចាត់ទុកថាជាបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធទេ លុះត្រាតែកម្មវិធីនេះដឹងច្បាស់ល្មមថាពួកគេស្របតាមនិយមន័យនៃទំនាក់ទំនងជិតស្និទ្ធខាងលើ។ បុគ្គលមិនគួរត្រូវបានគេចាត់ទុកថាជាបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធ ដោយសារតែពួកគេមានវត្តមាននៅក្នុងថ្នាក់ ឬក្រុមសាលារៀនដូចគ្នា ខណៈដែលមានមនុស្សមានជំងឺ COVID-19 ទាំងស្រុងនោះទេ។ ប្រសិនបើកម្មវិធីមិនអាចកំណត់បានថា តើអ្នកណាជាអ្នកដែលមានទំនាក់ទំនងជិតស្និទ្ធ ពួកគេគួរតែទាក់ទងសុខភាពសាធារណៈដើម្បីទទួលបានជំនួយផ្នែកបច្ចេកទេស។

# សម្រាប់កុមារដែលបានប៉ះពាល់នៅនឹងមេរោគ*៖ *តើការធ្វើចត្តាឡីស័កមានរយៈពេលយូរប៉ុណ្ណា?*

កុមារមានរោគសញ្ញា → ដោយមិនគិតពីស្ថានភាពចាក់ថ្នាំបង្ការ → ពិគ្រោះជាមួយអ្នកផ្តល់សេវាវេជ្ជសាស្ត្រ ដើម្បីធ្វើការវាយតម្លៃបន្ថែម → អនុវត្តតាមសេចក្តីណែនាំនៃការមិនរាប់បញ្ចូល ដោយអនុវត្តតាមវិធីសាស្ត្រសម្រេចចិត្តសម្រាប់កុមារដែលមានរោគសញ្ញារបស់ DPH (សូមមើលទំព័រទី 3)

---

**កុមារមិនមានរោគសញ្ញា**

- **មិនបានចាក់ថ្នាំបង្ការពេញលេញ**
  - __ការធ្វើចត្តាឡីស័កតាមទម្លាប់__ ការធ្វើតេស្តរកមេរោគត្រូវបានណែនាំឱ្យអនុវត្តយ៉ាងហ្មត់ចត់
    - ប្រសិនបើគ្មានការធ្វើតេស្តទេ បញ្ចប់ការធ្វើចត្តាឡីស័ក__បន្ទាប់ពី__ថ្ងៃទី 10
    - ប្រសិនបើប្រមូលបានលទ្ធផលនៃការធ្វើតេស្តអវិជ្ជមាននៅថ្ងៃទី 5 ឬបន្ទាប់ពីនេះ ចូរបញ្ចប់ការធ្វើចត្តាឡីស័ក__បន្ទាប់ពី__ថ្ងៃទី 7
  - __ជម្រើសនៃការធ្វើចត្តាឡីស័កសម្រាប់សិស្ស TK-12 ដែលបានកែសម្រួល **__ ធ្វើតេស្តពីរដងក្នុងមួយសប្តាហ៍រហូតដល់បញ្ចប់ការធ្វើចត្តាឡីស័ក (ការធ្វើតេស្តលើកទី 1នៅលើថ្ងៃទី 1 ឬ 2; ការធ្វើតេស្តលើកទី 2 នៅថ្ងៃទី 5)
    - សិស្សអាចចូលរៀនក្នុងថ្នាក់ដោយផ្ទាល់បាន ប៉ុន្តែបើមិនដូច្នេះទេ ត្រូវធ្វើចត្តាឡីស័កនៅផ្ទះ។ ប្រសិនបើប្រមូលបានលទ្ធផលនៃការធ្វើតេស្តអវិជ្ជមាន__នៅថ្ងៃទី 5 ឬបន្ទាប់ពីនេះ__ ចូរបញ្ចប់ការធ្វើចត្តាឡីស័ក__បន្ទាប់ពី__ថ្ងៃទី 7
- **[ចាក់ថ្នាំបង្ការពេញលេញ]** → ការធ្វើតេស្តរកមេរោគត្រូវបានណែនាំឱ្យអនុវត្ត → មិនចាំបាច់ធ្វើចត្តាឡីស័កទេ
- **ការជាសះស្បើយឡើងវិញពីជំងឺ COVID-19 ក្នុងអំឡុងពេល 90 ថ្ងៃមុន** → មិនចាំបាច់ធ្វើតេស្តរកមេរោគទេ → មិនចាំបាច់ធ្វើចត្តាឡីស័កទេ

ការតាមដានរោគសញ្ញារហូតដល់ថ្ងៃទី 14

*អនុវត្តតាម[សេចក្តីណែនាំនៃការធ្វើចត្តាឡីស័កនៅផ្ទះ]របស់នាយដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles។ ** ការធ្វើចត្តាឡីស័កដែលបានកែសម្រួលអនុវត្តតែចំពោះសិស្សសាលារៀន TK-12 ដែលបានប៉ះពាល់នឹងមេរោគនៅក្នុងទីតាំងសាលារៀនតែប៉ុណ្ណោះ។

# សម្រាប់បុគ្គលិកដែលបានប៉ះពាល់ទៅនឹងមេរោគ*៖ *តើការធ្វើចត្តាឡីស័កមានរយៈពេលយូរប៉ុណ្ណា?*

មានរោគសញ្ញា → ដោយមិនគិតពីស្ថានភាពចាក់ថ្នាំបង្ការ → ពិគ្រោះជាមួយអ្នកផ្តល់សេវាវេជ្ជសាស្ត្រ ដើម្បីធ្វើការវាយតម្លៃបន្ថែម → អនុវត្តតាមសេចក្តីណែនាំនៃការមិនរាប់បញ្ចូល ដោយអនុវត្តតាមវិធីសាស្ត្រសម្រេចចិត្តសម្រាប់បុគ្គលិកដែលមានរោគសញ្ញារបស់ DPH (សូមមើលទំព័រទី 7)

---

គ្មានរោគសញ្ញា

- មិនបានចាក់ថ្នាំបង្ការពេញលេញ → ការធ្វើតេស្តរកមេរោគត្រូវបានណែនាំឱ្យអនុវត្តយ៉ាងហ្មត់ចត់ →
  - ប្រសិនបើមិនធ្វើតេស្ត បញ្ចប់ការធ្វើចត្តាឡីស័កបន្ទាប់ពីថ្ងៃទី 10
  - ប្រសិនបើប្រមូលបានលទ្ធផលនៃការធ្វើតេស្តអវិជ្ជមាននៅថ្ងៃទី 5 ឬបន្ទាប់ពីនេះ៖ ចូរបញ្ចប់ការធ្វើចត្តាឡីស័កបន្ទាប់ពីថ្ងៃទី 7
- **ចាក់ថ្នាំបង្ការពេញលេញ** → ការធ្វើតេស្តរកមេរោគត្រូវបានណែនាំឱ្យអនុវត្ត → មិនចាំបាច់ធ្វើចត្តាឡីស័កទេ
- ការជាសះស្បើយឡើងវិញពីជំងឺ COVID-19 ក្នុងអំឡុងពេល 90 ថ្ងៃមុន → មិនចាំបាច់ធ្វើតេស្តរកមេរោគទេ → មិនចាំបាច់ធ្វើចត្តាឡីស័កទេ

តាមដានរោគសញ្ញារហូតដល់ថ្ងៃទី 14

*អនុវត្តតាម សេចក្តីណែនាំនៃការធ្វើចត្តាឡីស័កនៅផ្ទះ របស់នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles ដែលអនុញ្ញាតឱ្យបុគ្គលិកវិលត្រឡប់ទៅធ្វើការវិញភ្លាមៗ នៅពេលដែលពួកគេបញ្ចប់ការធ្វើចត្តាឡីស័កដោយមិនមានបញ្ហា ដែលអាចមុនពេលពួកគេបំពេញតាម លក្ខខណ្ឌសម្រាប់ការវិលត្រឡប់ទៅធ្វើការរបស់ Cal/OSHA។